# កិច្ចប្រជុំអន្តរក្រសួងស្តីពីការពិនិត្យការអនុវត្តវិធានការនានា
# របស់កម្ពុជាក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាន

កិច្ចប្រជុំអន្តរក្រសួង ស្តីពីការពិនិត្យការអនុវត្តវិធានការនានារបស់កម្ពុជាក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាន ត្រូវបាន ប្រារព្ធធ្វើឡើង នៅព្រឹកថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ២០១០ នៅទីស្តីការក្រសួង ក្រោមអធិបតីភាព ឯកឧត្តម **ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងជាប្រធានសហគមន៍សេដ្ឋកិច្ចអាស៊ាន សំរាប់កម្ពុជា ។

គោលបំណងនៃកិច្ចប្រជុំ គឺដើម្បីពិភាក្សាពិនិត្យឡើងវិញ ពីវិធានការ សកម្មភាព និងឯកសារគតិយុត្តិនានា របស់កម្ពុជា យោងតាមស្មារតីនៃសេចក្តីប្រកាសរួម ក្នុងការប្តេជ្ញាចិត្តឈានឆ្ពោះទៅបង្កើតសហគមន៍សេដ្ឋកិច្ច អាស៊ាន នៅឆ្នាំ២០១៥ ដែលមានគោលដៅចំបងចំនួន០៤ គឺៈ មូលដ្ឋានផលិតផល និងទីផ្សារតែមួយ-តំបន់សេដ្ឋកិច្ច ប្រកួតប្រជែង-អភិវឌ្ឍន៍សេដ្ឋកិច្ចប្រកបដោយសមភាព និងការធ្វើសមាហរណកម្ម សេដ្ឋកិច្ចក្នុងពិភពលោក ។

អង្គប្រជុំ បានធ្វើបទបង្ហាញតាមរបៀបវីរៈនីមួយៗ ដើម្បីពិនិត្យពិភាក្សាការអនុវត្តវិធានការនានារបស់ កម្ពុជា ក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាន ដោយបានធ្វើបទបង្ហាញអំពីតារាងពិន្ទុ នៃការអនុវត្តវិធានការណ៍នានា រួមមានៈវិធានការ ដែលបានអនុវត្ត និងមិនទាន់បានអនុវត្ត-ការងារផ្សព្វផ្សាយពីសហគមន៍សេដ្ឋកិច្ចអាស៊ាន ក្នុង កំរិតជាតិ និង ការធ្វើបទបង្ហាញ ស្តីពីកិច្ចព្រមព្រៀង និងពិធីសារ ដែលកម្ពុជាបានចូលរួមចុះហត្ថលេខា ទាំងក្នុង ក្របខ័ណ្ឌអាស៊ាន និងក្នុងក្របខ័ណ្ឌ អាស៊ាន ជាមួយដៃគូពិគ្រោះយោបល់ ។

ឯកឧត្តមទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** ក្នុងនាមជាប្រធានសហគមន៍សេដ្ឋកិច្ចអាស៊ានសំរាប់កម្ពុជា បានមាន ប្រសាសន៍ថាៈ ជោគជ័យនៃការបង្កើតសហគមន៍សេដ្ឋកិច្ចអាស៊ាន មានទំនាក់ទំនងយ៉ាងសំខាន់ជាមួយស្ថាប័នពាក់ ព័ន្ធទាំងអស់ ក្នុងការបង្កើតនូវឯកសារលំអិតមួយ ។ ក្នុងនោះកម្មវិធីទំនាក់ទំនងដ៏ល្អ គឺទាមទារឱ្យមានការយល់ដឹង ជ្រួតជ្រាបជាសាធារណៈ ក្នុងចំណោមប្រទេសជាសមាជិកអាស៊ាន និងអ្នកពាក់ព័ន្ធនានា រួមមានៈ មន្ត្រីរដ្ឋាភិបាល សហគមន៍ ពាណិជ្ជកម្ម និងប្រជាជនក្នុងបណ្តាប្រទេសអាស៊ានជាដើម ។ ឯកឧត្តមទេសរដ្ឋមន្ត្រី បានថ្លែងអំណរគុណ ដល់ក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ ដែលបានប្រឹងប្រែងអនុវត្តវិធានការនានា តាមវិស័យនីមួយៗ ក្នុងសហគមន៍ សេដ្ឋកិច្ចអាស៊ាន ដែលរហូតដល់ពេលនេះ កម្ពុជាទទួលបានចំណាត់ថ្នាក់លេខ០៣ ក្នុងចំណោមប្រទេសអាស៊ាន ទាំង១០ គឺអនុវត្តបាន៩០ វិធានការលើ១០៨ វិធានការស្មើនិង ៨៣,៣៣% ។ ឯកឧត្តមទេសរដ្ឋមន្ត្រី បានបញ្ជាក់ បន្ថែមថាៈ កម្ពុជា នឹងធ្វើជាម្ចាស់ផ្ទះ ក្នុងការរៀបចំកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រី និងកិច្ចប្រជុំកំពូលស្តីពីសហគមន៍ សេដ្ឋកិច្ច អាស៊ាន នៅក្នុងខែមេសា ឆ្នាំ២០១០ ខាងមុខ ។ ដូច្នេះ ឯកឧត្តមបានស្នើឱ្យក្រសួងស្ថាប័នពាក់ព័ន្ធទាំងអស់ ខិតខំ ពន្លឿនកិច្ចការរបស់ខ្លួន ហើយអ្វីដែលនៅសេសសល់ រឺមានសកម្មភាពបន្ថែម សូមផ្តល់ព័ត៌មាន រឺ ចំលើយមក ក្រសួងពាណិជ្ជកម្ម ដើម្បីក្រសួងរាយការណ៍បន្តទៅ លេខាធិការអាស៊ាន ។ ដោយឡែកកិច្ចព្រមព្រៀង រឺ វិធានការ នានា សំរាប់អនុវត្តក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាន ឯកឧត្តមទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** បានជំរុញឱ្យពិនិត្យពិភាក្សា ឱ្យបានឆាប់ ពិសេសគឺការបង្កើតជាក្រុមបកប្រែ ភាសាមួយ ដើម្បីឱ្យមានការឯកភាពគ្នា លើការប្រើប្រាស់ភាសា បច្ចេកទេស សំរាប់ដាក់ឆ្លងរាជរដ្ឋាភិបាល និងសភា អនុម័ត ។